


# ឆ្នាំសិក្សាទី៥ និង៦

## ឆ្នាំសិក្សាបឋមកំរិតខ្ពស់គឺជាតំណាក់កាលសំខាន់មួយ ព្រោះសិស្សរកមើលបញ្ហាប្រឈមថ្មី, ចង់ដឹងបន្ថែមអំពីពិភពលោកនៅជុំវិញពួកគេ និងចង់ដឹងពីភាពសំខាន់របស់ពួកគេចំពោះពិភពលោក។

ក្មេងៗនៅអាយុនេះចង់ចេះចង់ដឹងខ្លាំង, ពួកគេត្រូវបានដឹកនាំដោយព័ត៌មានសំបូរបែបដែលមានសំរាប់ពួកគេភ្លាមៗ និងមានគ្រប់ពេលលើអ៊ិនធើណេត។

យើងដឹងថាជីវិតរបស់ក្មេងអាយុ១១ឆ្នាំបច្ចុប្បន្នខុសប្លែកពីពេលឪពុកម្តាយពួកគេអាយុ១១ឆ្នាំច្រើនណាស់ និងគ្រូបង្រៀនដែលមានអាយុស្មើរគ្នា និងវិធីបង្រៀនចាស់ៗមិនអាចបំពេញតាមសមត្ថភាព និងការយល់ដឹងរបស់សិស្សឆ្នាំសិក្សាទី៥ និងទី៦បានទេ។ នេះជាហេតុផលដែលយើងបានបង្កើតកម្មវិធីដែលមានតែមួយមួយសំរាប់អ្នកសិក្សានៅតំណាក់កាលនេះ, ដែលវាត្រូវបានរចនាឡើងដើម្បីបង្ហាញពួកគេពីភាពលំបាកដែលពួកគេចង់បាន និងបណ្តុះទឹកចិត្តស្រលាញ់ការសិក្សាដែលនឹងស្ថិតនៅជាមួយពួកគេរហូតដល់ថ្នាក់មធ្យមសិក្សា និងយូរអង្វែងតទៅទៀត។

សិស្សឆ្នាំទី៥ និងទី៦របស់យើងទទួលបានការអប់រំពីអ្នកជំនាញលើគ្រប់មុខវិជ្ជាទាំងអស់។ ពួកគេសិក្សាគណិតវិទ្យាពីគណិតវិទូ ហើយសិក្សាវិទ្យាសាស្រ្តពីអ្នកវិទ្យាសាស្រ្ត។ កម្មវិធីសិក្សារួមមាន ភាសាអង់គ្លេស, វិទ្យាសាស្រ្ត, គណិតវិទ្យា, មនុស្សធម៌, ភាសា (ចិន, បារាំង ឬអេស្ប៉ាញ), បច្ចេកវិទ្យាឌីជីថល, កាយវប្បកម្ម, ការសិក្សាក្នុងបណ្ណាល័យ, សិល្បៈ និងតន្រ្តី, ទាំងអស់បង្រៀនដោយគ្រូជំនាញ និងក្នុងថ្នាក់រៀនអ្នកជំនាញ។ នេះធ្វើឱ្យសិស្សចូលរួមកាន់តែស៊ីជម្រៅ និងមានអត្ថន័យជាមួយនឹងមាតិកាកម្មវិធីសិក្សា ហើយធ្វើអោយគេចាប់ផ្តើមស្វែងយល់ពីវិស័យ និងជំនាញដែលគេមានចំណាប់អារម្មណ៍លើ។

កម្មវិធីរបស់យើងផ្តល់អោយសិស្សឆ្នាំទី៥ និងទី៦នូវការប្រឈមមុខចំពោះការសិក្សា, ដើម្បីធានាថាពួកគេបន្តការចូលរួម និងរីករាយក្នុងការសិក្សា, ហើយក៏សាងអារម្មណ៍សិក្សា, ទំនុកចិត្ត និងជំនាញគិតអោយបានល្អិតល្អន់ក្នុងខ្លួនរបស់ពួកគេ ដែលពួកគេនឹងត្រូវការដើម្បីប្រឈមនឹងអនាគតរបស់ពួកគេ។